**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# លិខិតអបអរសាទរ

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីត្រេកអរ រំភើប និងចូលរួមអបអរសាទរយ៉ាងក្លៀវក្លាចំពោះខួប៣០ឆ្នាំ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (២៣ តុលា ១៩៩១-២៣ តុលា ២០២១) និងក៏ជាខួប៣០ឆ្នាំ នៃការយាងនិវត្តន៍របស់ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** មកកាន់មាតុភូមិវិញ។ នេះជាសក្ខីភាពមួយនៃការចងចាំជាអមតៈនូវព្រះរាជកិច្ចដ៏មហាថ្លៃថ្លារបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** និង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តួចផ្តើមស្វែងរកការឯកភាពជាតិ តាមរយៈធ្វើឱ្យមានការចាប់បដិសន្ធិនូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលធ្វើឱ្យកម្ពុជាមានវឌ្ឍនភាពប្រកបដោយភាពវិជ្ជមាន ក្នុងរយៈពេល៣០ឆ្នាំកន្លងទៅនេះ។

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ ពិតជាចងចាំមិនភ្លេចនូវវីរភាពប្រកបដោយទឹកព្រះទ័យស្នេហាជាតិមាតុភូមិកម្ពុជា និងប្រជាជាតិរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** និងវីរភាពរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលជាតួអង្គដ៏សំខាន់បំផុតក្នុងការគោរពអនុវត្តនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដ៏ស្មោះត្រង់សំដៅរក្សាការពារសុខសន្តិភាព និងអភិវឌ្ឍន៍រហូតមកដល់បច្ចុប្បន្ន។

យើងខ្ញុំទាំងអស់គ្នា សូមធ្វើការប្តេជ្ញាចិត្តប្រកបដោយឆន្ទៈ ចូលរួមគ្រប់សកម្មភាពដោយឥតងាករេជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបាននាំមកនូវសុខសន្តិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ ឯករាជ្យភាពជាតិ អធិបតេយ្យភាពជាតិ និងបន្តអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពនៅព្រះរាជាណាចក្រកម្ពុជា។

សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ១រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
រដ្ឋមន្ត្រី

ព្រុំ-សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh